# ១-រឿង មនុស្សពីរនាក់នៅផ្ទះជិតគ្នា




កាលពីព្រេងនាយ មានមនុស្សពីរនាក់នៅផ្ទះជិតគ្នា ។ ថ្ងៃមួយចៅទាំងពីរនាក់នោះបបួលគ្នាទៅដាក់អន្ទាក់សត្វ ។ បបួលគ្នាហើយ ដល់ថ្ងៃរសៀលគងភ្នំ ក៏នាំគ្នាដើរចេញទៅ ។ លុះដល់ព្រៃជាកន្លែងដាក់អន្ទាក់ អ្នកមួយថា « ខ្ញុំនឹងដាក់នៅគល់ឈើនេះ ត្បិតឈើនេះមានផ្លែ យប់ៗសត្វចំណាំតែមកស៊ីផ្លែឈើនេះ» ។ អ្នកមួយទៀត ឆ្លើយថា «ខ្ញុំក៏ចង់ដាក់កន្លែងហ្នឹងដែរ ប៉ុន្តែឥឡូវ បើអ្នកដាក់នៅគល់ឈើ មានតែខ្ញុំដាក់នៅចុងឈើ រួចយើងចាំមើល ព្រឹកឡើងរបស់អ្នកណាជាប់សឹមដឹង» និយាយគ្នាហើយ ម្នាក់ដាក់នៅគល់ឈើស្រេចហើយ វិលមកផ្ទះវិញ លាគ្នាទៅផ្ទះតែរៀងខ្លួន ។ ឯអ្នកដាក់អន្ទាក់នៅចុងឈើនោះ លុះវិលមកដល់ផ្ទះហើយយប់នោះគិតគ្នាពីរនាក់ប្តីប្រពន្ធថា តាំងពីដូនតាមកមិនដែលឮថាអ្នកឯណាដាក់អន្ទាក់លើចុងឈើ ឲ្យជាប់សត្វជើងបួនដែលដើរនៅលើដីទេ ឥឡូវនេះ អញដាក់នៅលើចុងឈើ តើធ្វើម្តេចនឹងបានសត្វ? ដូច្នេះ ត្រូវអញរពុកពីពេលមាន់រងាវទៅមើល បើឃើញសត្វជាប់អន្ទាក់គេនៅដី អញដោះយកទៅចងនឹងអន្ទាក់អញឯចុងឈើ ដល់ព្រឹកឡើងអញទៅមើលជាមួយអ្នកនោះហើយអញដោះយកសត្វទៅជូនលោកសុភាសេក បើវាមិនសុខចិត្តដូចម្តេចៗ មុខជាកើតក្តី គង់តែដល់សុភាសេកមិនខាន សុភាសេកនិងកាត់ក្តីឲ្យវាចាញ់ជាប្រាកដ ។ ប្តីប្រពន្ធគិតគ្នាហើយដេកទៅ ដល់មាន់រងាវរពុកពីដេកលប់មុខស៊ីស្លា ហើយចេញពីផ្ទះដើរដល់អន្ទាក់បានឃើញអន្ទាក់នៅដីជាប់ក្តាន់ ១ក៏ដោះយកឡើងទៅចងនឹងអន្ទាក់របស់ខ្លួន រួចដំឡើងអន្ទាក់នៅដីដូចដើមក៏ប្រញាប់វិលមកផ្ទះវិញ ។ លុះព្រឹកព្រហាមស្រាងៗឡើង អ្នកមួយដែលដាក់អន្ទាក់នៅដី មកស្រែកហៅឲ្យទៅមើលអន្ទាក់អ្នកមួយ ឆ្លើយថា កុំរលះរលាំងថ្វី អន្ទាក់ខ្ញុំ ខ្ញុំមិនសង្ឃឹមទេ ត្បិតនៅលើចុងឈើ ក្រែងតែអន្ទាក់អ្នកនៅដីនោះ ខ្ញុំមិនហ៊ានថា បើបានចែកគ្នាស៊ីផង ។ ពាក្យនេះជាពាក្យចំអកឲ្យអ្នកមួយ ត្បិតដឹងការណ៍មុនហើយ ។ អ្នកទាំងពីរនិយាយហើយចុះពីផ្ទះដើរចេញទៅ លុះដើរទៅដល់មិនឃើញអន្ទាក់នៅដីជាប់សត្វ ឃើញតែអន្ទាក់នៅលើចុងឈើជាប់វិញ ។ ចៅដែលជាម្ចាស់អន្ទាក់នៅចុងឈើថា «ហ្ន មើលចុះ មិនជឿខ្ញុំ ខ្ញុំថាកុំដាក់នៅគល់ឲ្យដាក់នៅចុងឥឡូវ មើលរបស់អ្នកណាជាប់ហ:?» ហើយឡើងទៅដោះយកសត្វចុះមកនាំគ្នាវិលមកផ្ទះវិញ ក៏លាគ្នាទៅផ្ទះដោយខ្លួនទៅ ។ ឯចៅដែលបានក្តាន់ ក៏ប្រញាប់យកទៅជូនសុភាសេកហើយជម្រាបថា «ខ្ញុំហើយនឹងចៅមួយនោះ ទៅដាក់អន្ទាក់ផងគ្នា ខ្ញុំដាក់នៅចុងឈើ អ្នកមួយនោះដាក់នៅគល់ឈើ ខ្ញុំនេះជាមនុស្សរៀច ក្តីនេះគង់តែមកដល់លោកដូច្នេះ តាមតែលោកមេត្តារកសេចក្តីយ៉ាងណា ឲ្យតែក្តីខ្ញុំឈ្នះវាចុះ ខ្ញុំនឹងដឹងគុណលោកទៅថ្ងៃមុខ» ។ សុភាសេកបានសាច់ក្តាន់ហើយ ឆ្លើយថា «ឯងទៅរកស្លាម្លូមកឲ្យឆាប់ឲ្យទាន់ព្រឹកនេះ បើវាមកប្តឹងអញៗបង្គាប់អីចឹងដែរ បើវាមកមិនទាន់ អញនិងកាត់សេចក្តីឲ្យវាចាញ់បានដោយងាយ ឯងប្រញាប់ទៅចុះ» ។ ឯអ្នកដែលដាក់អន្ទាក់លើគល់ឈើ លុះវិលមកផ្ទះហើយ ដង្ហើមតូចដង្ហើមធំមិនសុខចិត្តក៏យកសេចក្តីទៅប្តឹងសុភាសេក ។ ក៏បង្គាប់សេចក្តីដូចបង្គាប់ចៅមុន ។ លុះព្រឹកឡើង អ្នកដែលដាក់អន្ទាក់នៅលើចុងឈើ ក៏យកឥវ៉ាន់ទៅដល់មុន ។ ឯអ្នកដែលដាក់អន្ទាក់នៅដី ដោយខ្លួនជាអ្នកក្រលំបាកតោកយ៉ាក ដើររកទិញអីវ៉ាន់ពុំបានពុំទាន់ ភ័យក្រែងខ្លួនចាញ់គេ ហើយគេ

យកទោសផង ក៏រត់ពីភូមិមួយទៅភូមិមួយបានជួបនឹងសុភាទន្សាយៗសួរថា «មានដំណើរអីបានជារត់ដូច្នេះ ? ឈប់សិន » ។ ចៅនោះឆ្លើយថា «លោកអើយអាណិតដោះទុក្ខខ្ញុំផង ត្បិតខ្ញុំហើយនឹងអ្នកមួយទៅដាក់អន្ទាក់ផងគ្នា ខ្ញុំដាក់នៅគល់ឈើ គេដាក់នៅចុងឈើ ព្រឹកឡើងទៅមើលពុំឃើញអន្ទាក់នៅដីជាប់សត្វ ឃើញតែអន្ទាក់នៅចុងឈើជាប់ក្ដាន់មួយ ខ្ញុំមិនសុខចិត្តបានយកសេចក្ដីទៅប្ដឹងសុភាសេកៗ គេថា អ្នកណាយកអីវ៉ាន់ទៅដល់មុន អ្នកនោះឈ្នះ ហេតុនេះបានជាខ្ញុំភ័យ ឥឡូវគេទៅដល់មុនខ្ញុំហើយ ដូច្នេះតាមតែលោកអាណិតខ្ញុំផង» ។ សុភាទន្សាយឆ្លើយថា «ណ្ហើយ ! កុំភ័យចាំថ្ងៃរសៀលខ្ញុំនឹងនាំទៅ»។ ចៅនោះក៏អរ ។ លុះដល់ថ្ងៃរសៀល សុភាទន្សាយទៅដល់ផ្ទះសុភាសេក ៗស្រែកសួរមកថា «ដូចម្ដេចក៏យូរម្ល៉េះ ? ក្ដីចាញ់គេហើយ» ។ សុភាទន្សាយឆ្លើយថា «យើងខ្ញុំបានជាយូរនេះ ពីព្រោះអាល័យតែមើលត្រីក្រាញ់ហើរឡើងស៊ីស្លឹកអំពិល» ។ សុភាសេកថា «ពីជីដូនជីតាមកគ្មាននរណាដែលឃើញដែលឮថា ត្រីក្រាញ់ឡើងស៊ីស្លឹកអំពិលទេ» ។ សុភាទន្សាយឆ្លើយថា «ពីជីដូនជីតាពីម៉ែពីឪបង្កើតមក នរណាដែលឃើញដែលឮថា អន្ទាក់នៅដីមិនជាប់សត្វទៅជាប់ឯអន្ទាក់នៅចុងឈើវិញ ហើយសត្វជើងបួនផង, ដែលឮទេអស់អ្នកស្រុក ? នោះសុភាសេកស្ងៀមពុំហ៊ានស្ដីតបទៀត ។ សុភាទន្សាយក៏កាត់សេចក្ដីឲ្យចៅដែលដាក់អន្ទាក់នៅដីឈ្នះ ។ ឯសុភាសេកដែលអង្គុយធ្វើជាសុភានោះ ក៏ខ្មាសដោយសារខ្លួនជាអ្នកល្មោភជំនួនសាច់ក្ដាន់ ក៏ស្ងៀមបែរមុខផ្ទប់ទៅខាងជញ្ជាំងដូចឆ្មាលបកណ្ដុរ ។

> ***លោភឥតខ្មាស វិនាសច្បាប់***


g+1 +1 Recommend this on Google

# Tablet Angebote

Tablets mit o2 Go Flat wählen & 240€ sparen. Jetzt mobil bestellen.


ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ


